OCHCA

# ការតាមដានរកអ្នកប៉ះពាល់ v3

## SCRIPT

ក្នុងគ្រាមានវិបត្តិ សកម្មភាពនៅទូទាំងសហគមន៍ជំរុញឲ្យមានក្តីសង្ឃឹម និងការជាសះស្បើយ។ ដើម្បីការពារប្រជាពលរដ្ឋរបស់យើង OC Health Care Agency កំពុងដាក់ដំណើរការមុខងារតាមដានរកអ្នកប៉ះពាល់ - ដែលជាប្រព័ន្ធជូនដំណឹង និងគាំទ្រដែលត្រូវបានបង្កើតឡើងដើម្បីបន្ថយល្បឿន និងបញ្ឈប់ការឆ្លងរីករាលដាលនៃមេរោគកូរ៉ូណាថ្មី។

ឥឡូវនេះក្រុមអ្នកជំនាញផ្នែកស៊ើបអង្កេតករណី និងការប៉ះពាល់ (Case and Contact Investigation) កំពុងធ្វើការបញ្ជាក់ករណីនៃការឆ្លងមេរោគ កំណត់ករណីប៉ះពាល់ដែលអាចកើតឡើង និងលើកកម្ពស់សុខភាពនាពេលអនាគតប្រកបដោយប្រសិទ្ធភាពខ្ពស់។

នេះជារបៀបដែលប្រព័ន្ធនេះដំណើរការ៖

នៅពេលពលរដ្ឋធ្វើតេស្តរោគវិនិច្ឆ័យ PCR ហើយលទ្ធផលតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 សូមរាយការណ៍ទៅក្រុម CCI របស់យើង។ បន្ទាប់មកអ្នកតាមដានរកអ្នកប៉ះពាល់ម្នាក់របស់យើងដែលបានទទួលការបណ្តុះបណ្តាលនឹងទាក់ទងជននោះ ដើម្បីធានាថាគាត់មានសមត្ថភាពក្នុងការនៅដាច់ដោយឡែក និងបំពេញតម្រូវការប្រចាំថ្ងៃ។

TEXT BOX:
បើអ្នកបានធ្វើតេស្តបានលទ្ធភាពវិជ្ជមាន ហើយត្រូវការជំនួយ និងមិនទាន់បានឮពីយើង ក្រុមបញ្ជូនទៅទទួលសេវាសុខភាពរបស់យើងប្រចាំការនៅទីនេះដើម្បីផ្តល់ជំនួយតាមរយៈលេខ (800) 564-8448។

ផ្អែកលើការកំណត់ពេលវេលាដឹងពីរោគសញ្ញារបស់បុគ្គល យើងនឹងបង្កើតបញ្ជីឈ្មោះមនុស្សបន្ថែមដែលអាចរងការប៉ះពាល់ផងដែរ ហើយផ្តល់ជូនពួកគេនូវការណែនាំផ្ទាល់ខ្លួនអំពីប្រធានបទដូចជាការធ្វើតេស្ត ការព្យាបាល និងការថែទាំសុខភាព។

នៅពេលដែល HCA នៅតែបន្តប្រើប្រាស់ប្រព័ន្ធតាមដានរកអ្នកប៉ះពាល់ និងការស៊ើបអង្កេតករណីដើម្បីធានាថាបងប្អូនប្រជាពលរដ្ឋរបស់យើងទទួលបានការគាំទ្រ និងធនធានចាំបាច់ដែលយើងត្រូវការ យើងសូមថ្លែងអំណរគុណអ្នកដែលបានបំពេញតួនាទីរបស់អ្នកដើម្បីអនុវត្តការឃ្លាតឆ្ងាយពីគ្នា ពាក់ម៉ាស់ឲ្យបានត្រឹមត្រូវ និងធ្វើចត្តាឡីស័កដោយខ្លួនឯង ប្រសិនបើចាំបាច់។

ចំពោះធនធានបន្ថែមអំពីជំងឺ COVID-19 សូមចូលមើលគេហទំព័រ ochealthinfo.com/novelcoronavirus។